# ការណែនាំ និងបញ្ជីឯកសារនានា
# សម្រាប់ត្រៀមរៀបចំការចូលរួមកិច្ចប្រជុំក្រុមការងារខេមមីតថ្នាក់តំបន់
# និងកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់លើកទី១៤ ឆ្នាំ២០២០

<u>បទបង្ហាញសម្រាប់កិច្ចប្រជុំក្រុមការងារខេមមីតថ្នាក់តំបន់(TF) ១៥ ធ្នូ ២០២០៖</u>

១. **បទបង្ហាញទី១៖** ស្ថានភាពជួញដូរមនុស្សដែលកើតឡើងថ្មីៗ និងវឌ្ឍនភាពនៃខេមមីត (បទបង្ហាញមានរយៈពេលតិចជាង៦នាទី) (យ៉ាងច្រើនបំផុត ៣ ឬ៤ស្លាយ)

- សង្ខេបខ្លីបំផុតនៃការអភិវឌ្ឍជាគន្លឹះនៃស្ថានភាពជួញដូរមនុស្សក្នុងប្រទេស មុនពេលរៀបរាប់ពីវឌ្ឍនភាពទូទៅក្នុងផ្នែកទាំង៦ ឬផ្នែកខ្លះនៃ SPAIV។
- កំណត់សម្គាល់៖ បទបង្ហាញនេះនឹងផ្តល់ឱកាសមួយសម្រាប់សង្ខេបពីការអភិវឌ្ឍសំខាន់ៗ និងការវាយ តម្លៃជាក់ស្តែងលើវឌ្ឍនភាពទូទៅ ដោយលើកជាឧទាហរណ៍បង្ហាញពីការរីកចម្រើន និងឧបសគ្គ។

២. **បទបង្ហាញទី២៖** ការធ្វើបច្ចុប្បន្នភាពនៃការអភិវឌ្ឍ និងការអនុវត្ត NRM/TRM (បទបង្ហាញមានរយៈពេលតិចជាង៦នាទី) (យ៉ាងច្រើនបំផុត ៣ ឬ៤ស្លាយ)

- ការណែនាំខ្លីអំពីលទ្ធផលសំខាន់ៗ ដែលសម្រេចបានដោយរដ្ឋាភិបាល ចំពោះការកសាង និងអនុវត្តយន្តការជាតិបញ្ជូន (NRM) និងការពង្រឹងយន្តការបញ្ជូនឆ្លងដែន (TRM)។ បើអាចគួរដាក់បញ្ចូលព័ត៌មានមួយចំនួនដូចតទៅ៖
  - ចំនួនជនរងគ្រោះដែលបានកំណត់អត្តសញ្ញាណ និងបានបញ្ជូនទៅរកសេវា នៅឆ្នាំ២០២០
  - ចំនួនជនរងគ្រោះដែលបានបញ្ជូនទៅកាន់/ទទួលពីប្រទេសខេមមីត
  - គោលនយោបាយ ឬគោលការណ៍ណែនាំថ្មី និងការអនុវត្ត ឬផែនការសម្រាប់អនុវត្តថ្នាក់ជាតិ
  - ដំណើរការបញ្ជូនឆ្លងដែនជាមួយប្រទេសដទៃទៀត។

## ប្រធានបទដែលត្រូវពិភាក្សាក្នុងកិច្ចប្រជុំក្រុមការងារខេមមីតថ្នាក់តំបន់៖

- ឱកាស និងឧបសគ្គទាក់ទងទៅនឹងការបញ្ជូនឆ្លងដែន និងជម្រើសសម្រាប់យន្តការបញ្ជូនឆ្លងដែនសម្រាប់មហាអនុតំបន់មេគង្គ

- តើអ្វីទៅនឹងបន្តពី ផែនការមេហាអនុតំបន់ទី៤ (SPAIV) ៖ បន្តពី SPA បច្ចុប្បន្ន ឬកែសម្រួលឡើងវិញ ឬបង្កើត SPA ថ្មី។
- ការបន្តការគាំទ្ររបស់អង្គការ UNDP ដល់ខមមីត តាមរយៈគំនិតផ្តួចផ្តើមនៃទេសន្តរប្រវេសន៍ និងការភៀសខ្លួន។

<u>**បទបង្ហាញសម្រាប់កិច្ចប្រជុំមន្ត្រីជាន់ខ្ពស់លើកទី១៤ (SOM14) ១៦ ធ្នូ ២០២០៖**</u>

១. **បទបង្ហាញទី១៖** ការធ្វើបច្ចុប្បន្នភាពនៃវឌ្ឍនភាពអនុវត្ត SPAIV ក្នុងឆ្នាំ២០១៩-២០២០ ដោយផ្តោតលើ NRM/TRM ។ (បទបង្ហាញមានរយៈពេលតិចជាង៦នាទី) (យ៉ាងច្រើនបំផុត ៣ ឬ៤ស្លាយ)។

- បទបង្ហាញនេះគួរលើកយក ពីការសង្ខេបខ្លីពីវឌ្ឍនភាពចំពោះការអនុវត្ត SPAIV ដោយផ្តោតលើខ្លឹមសារនៃ NRM/TRM ដែលមាននៅក្នុងបទបង្ហាញនៅថ្ងៃដំបូង។

២. **បទបង្ហាញទី២៖** ផលប៉ះពាល់នៃជំងឺកូវីដ១៩ លើអំពើជួញដូរមនុស្ស និងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។ (បទបង្ហាញមានរយៈពេលតិចជាង៦នាទី) (យ៉ាងច្រើនបំផុត ៣ ឬ៤ស្លាយ)។ បទបង្ហាញគួរផ្តោតលើ៖

- ការវិភាគដ៏ខ្លីនៃបញ្ហា ដែលពន្យល់អំពីជំងឺកូវីដ១៩បង្កជាឧបសគ្គដល់ការអនុវត្តសកម្មភាព
- ពិភាក្សាអំពីជំហានដែលត្រូវចាត់ការដើម្បីសម្រេចបានលើឧបសគ្គទាំងនេះ និងលើកពីអនុសាសន៍នៃជំហានដោះស្រាយសម្រាប់ប្រទេសសមាជិកខមមីតផ្សេងទៀត ជួយសម្រេចដោះស្រាយបញ្ហា។

៣. **ការជ្រើសរើសប្រធានបទរបស់ប្រទេសនីមួយៗមកបង្ហាញតាមការស្ម័គ្រចិត្ត៖** តាមការស្ម័គ្រចិត្តរបស់ប្រទេសនីមួយដែលចង់ធ្វើបទបង្ហាញខ្លីអំពីករណី ឬវិធីសាស្ត្រថ្មីៗក្នុងការដោះស្រាយអំពើជួញដូរមនុស្សដែលឧទាហរណ៍។ បទបង្ហាញនីមួយៗមានរយៈពេលមិនលើសពី៦នាទី។

- ណែនាំពីវិធីសាស្ត្រថ្មីៗ និងបញ្ហាជាក់លាក់ដែលបានដោះស្រាយ ដោយផ្តោតលើការចែករំលែកបទពិសោធជាមេរៀន ដែលប្រទេសផ្សេងទៀតអាចអនុវត្តតាមបាន។
- <u>កំណត់សម្គាល់៖</u> អាចមានពេលវេលាសម្រាប់ការពិភាក្សា របស់ប្រទេសផ្សេងទៀតដែលចង់បន្ថែមជាមេរៀន ឬបទពិសោធល្អៗ ឬរបកគហើញថ្មីៗ ដោយមិនបាច់ធ្វើជាបទបង្ហាញ។

**ផ្នែកដែលត្រូវពិភាក្សាក្នុង SOM14៖**

ដៃគូរដ្ឋាភិបាលនឹងត្រូវបានបង្ហាញដោយសង្ខេបនូវផ្នែកមួយចំនួនដូចខាងក្រោម ដើម្បីឱ្យពួកគេអាចចូលរួមពិភាក្សាបាន៖

- ឱកាស និងឧបសគ្គទាក់ទងទៅនឹងការបញ្ជូនឆ្លងដែន និងជម្រើសសម្រាប់យន្តការបញ្ជូនឆ្លងដែនសម្រាប់មហាអនុតំបន់មេគង្គ
- តើអ្វីទៅនឹងបន្តពី ផែនការមហាអនុតំបន់ទី៤ (SPAIV) ៖ បន្តពី SPA បច្ចុប្បន្ន ឬកែសម្រួលឡើងវិញ ឬបង្កើត SPA ថ្មី។
- ការបន្តការគាំទ្ររបស់អង្គការ UNDP ដល់ខមមីត តាមរយៈគំនិតផ្តួចផ្តើមនៃទេសន្តរប្រវេសន៍ និងការកៀសខ្លួន។
- ក្នុងពេលវេទិកាសង្គមស៊ីវិល និងយុវជន រដ្ឋាភិបាលអាចមានសំណួរសួរអំពីបទបង្ហាញរបស់សង្គមស៊ីវិល និងក្រុមយុវជន។

## បញ្ជីឯកសារពាក់ព័ន្ធនានា៖

| ឯកសារ | កិច្ចប្រជុំ | កាលកំហិតសម្រាប់ផ្តល់ឯកសារជាភាសាខ្មែរ ដល់ **UN-ACT ថ្នាក់ជាតិ** | កាលកំហិតសម្រាប់ផ្តល់ឯកសារជាភាសាអង់គ្លេស ដល់ **UN-ACT ថ្នាក់តំបន់** |
|---|---|---|---|
| **បទបង្ហាញទី១៖** ស្ថានភាពជួញដូរមនុស្សដែលកើតឡើងថ្មីៗ និងវឌ្ឍនភាពនៃខមមីត | RTF | ៩ ធ្នូ ២០២០ | ១១ ធ្នូ ២០២០ |
| **បទបង្ហាញទី២៖** ការធ្វើបច្ចុប្បន្នភាពនៃការអភិវឌ្ឍនិងការអនុវត្ត NRM/TRM | RTF | ៩ ធ្នូ ២០២០ | ១១ ធ្នូ ២០២០ |
| **បទបង្ហាញទី១៖** ការធ្វើបច្ចុប្បន្នភាពនៃវឌ្ឍនភាពអនុវត្ត SPAIV ក្នុងឆ្នាំ២០១៩-២០២០ ដោយផ្តោតលើ NRM/TRM | SOM | ៩ ធ្នូ ២០២០ | ១១ ធ្នូ ២០២០ |
| **បទបង្ហាញទី២៖** ផលប៉ះពាល់នៃជំងឺកូវីដ១៩ លើអំពើជួញដូរមនុស្ស និងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស | SOM | ៩ ធ្នូ ២០២០ | ១១ ធ្នូ ២០២០ |

| | | | |
|---|---|---|---|
| **ការជ្រើសរើសប្រធានបទ៖**<br>តាមការស្ម័គ្រចិត្តរបស់ប្រទេសនីមួយដែលចង់ធ្វើបទបង្ហាញខ្លីអំពីករណី ឬវិធីសាស្រ្តថ្មីៗក្នុងការដោះស្រាយអំពើជួញដូរមនុស្ស ដែលឧទាហរណ៍ | SOM | ៩ ធ្នូ ២០២០ | ១១ ធ្នូ ២០២០ |
| | កិច្ចប្រជុំសង្គមស៊ីវិល/យុវជន និង SOM | | សេចក្តីព្រាងដំបូង៖ មុនថ្ងៃ១០ ធ្នូ ២០២០<br>បទបង្ហាញចុងក្រោយ៖ ថ្ងៃ១០ ធ្នូ ២០២០ |